JICA Cambodia Office - JICA カンボジア事務所

July 25 ·

[កិច្ចប្រជុំលើកទី៦ របស់គណៈកម្មការសម្របសម្រួល នៃគម្រោងពង្រឹងប្រព័ន្ធបណ្តុះបណ្តាលក្នុងពេលបម្រើការងារនៅប្រទេសកម្ពុជា (JCC)/ The 6th Joint Coordination Committee Meeting (JCC) of the Strings Project]

------------------------------

នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៥ កិច្ចប្រជុំលើកទី៦ របស់គណៈកម្មការសម្របសម្រួល នៃគម្រោងពង្រឹងប្រព័ន្ធបណ្តុះបណ្តាលក្នុងពេលបម្រើការងារនៅប្រទេសកម្ពុជា (Strings Project) ត្រូវបានរៀបចំឡើងនៅក្រសួងសុខាភិបាល ក្រោមកិច្ចសហប្រតិបត្តិការរវាង ក្រសួងសុខាភិបាល និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (ចៃកា)។ កិច្ចប្រជុំនេះដឹកនាំដោយ ឯកឧត្តមសាស្ត្រាចារ្យ ធា គ្រុយ រដ្ឋលេខាធិការ នៃក្រសួងសុខាភិបាល និងជានាយកគម្រោង ហើយក៏មានការចូលរួមពីភាគីពាក់ព័ន្ធសំខាន់ៗជាច្រើនទៀត រួមមាន ប្រធានគ្រប់គ្រង និងសម្របសម្រួលគម្រោង អ្នកតំណាងពីស្ថានទូតជប៉ុន ចៃកា និងតំណាងមកពីស្ថាប័នពាក់ព័ន្ធនានា។

កិច្ចប្រជុំនេះមានគោលបំណងចែករំលែកនូវវឌ្ឍនភាពនៃគម្រោងចាប់ពីខែធ្នូ ឆ្នាំ២០២៤ ដល់ខែមិថុនា ឆ្នាំ២០២៥ និងផែនការសម្រាប់ខែកក្កដា ដល់ខែធ្នូ ឆ្នាំ២០២៥ ហើយក៏មានការពិភាក្សាពីផែនការសកម្មភាពបន្ទាប់ផងដែរ។ ប្រធានគ្រប់គ្រង និងសម្របសម្រួលគម្រោងបានបង្ហាញពីវឌ្ឍនភាព និងលទ្ធផលសរុបនៃគម្រោង។ ចំណែកឯ ប្រធានទីប្រឹក្សាគម្រោង បានរាយការណ៍ពីការអនុវត្តការបណ្តុះបណ្តាលគ្រូបង្គោលវគ្គ៣ នៅខេត្តបាត់ដំបង និងខេត្តកំពង់ចាមផងដែរ។ ក្នុងនោះតំណាងខេត្តសាកល្បងទាំងពីរ ក៏បានបង្ហាញផែនការបណ្តុះបណ្តាលក្នុងពេលបម្រើការងារ (INSET) និងមានការចូលរួមចែករំលែកពីតំណាងក្រសួងសុខាភិបាល ពាក់ព័ន្ធនឹងផែនការសកម្មភាព INSET សម្រាប់រយៈពេល៦ខែខាងមុខ និងសកម្មភាព នៃ E-learning ផងដែរ។

ក្នុងអំឡុងពេលពិភាក្សានេះ ប្រធានគ្រប់គ្រង និងសម្របសម្រួលគម្រោង បានបង្ហាញពីផែនការដើម្បី អនុវត្តវគ្គបណ្តុះបណ្តាលសម្រាប់គ្រូបង្គោលទូទាំងប្រទេស ហើយសមាជិកអង្គប្រជុំទាំងអស់បានផ្លាស់ប្តូរយោបល់យ៉ាងសកម្ម និងបានពិភាក្សាអំពីវិធីសាស្ត្រដែលអាចអនុវត្តបានផងដែរ។ ដោយសារពេលវេលាមានកំណត់ និងបញ្ហាមួយចំនួននៅតែមាន យើងនឹងនៅតែបន្តខិតខំប្រឹងប្រែងទៀតបន្ទាប់ពីកិច្ចប្រជុំនេះ។ គម្រោងនឹងបន្តសហការ និងធ្វើការរួមគ្នាយ៉ាងជិតស្និតជាមួយក្រសួងសុខាភិបាល និងដៃគូពាក់ព័ន្ធនានា ដើម្បីសម្រេចបាននូវគោលដៅរួមនៃគម្រោង៕

On 16th July 2025, the 6th Joint Coordination Committee Meeting (JCC) of the Project for Strengthening In-Service Training System in Cambodia (Strings Project) was held by the Ministry of Health (MoH), co-organized with JICA. The meeting was chaired by H.E. Prof. THIR Kruy, Secretary of State of the MoH, the Project Director and attended by the key stakeholders including the Project Manager, the Embassy of Japan, JICA and other representatives from relevant organizations. The meeting aimed to review progress from December 2024 to June 2025, share plans for July to December 2025, and discuss the future activity plans. The Project Manager presented the overall progress and outputs of the Project. The Chief Advisor reported the completion of the Third round of Training of Trainers for In-Service Training (INSET) trainers in Battambang and Kampong Cham. Provincial representatives presented their INSET plans and the representatives from the MoH shared overall INSET related activities planned for the next 6 months and progress and upcoming activities of the e-learning platform.

During the discussion, the Project Manager introduced a potential plan for the nationwide training of trainer rollout. Participants actively exchanged views and discussed possible approaches. As several issues remain, further coordination will be needed beyond the JCC meeting. The Project will continue to closely collaborate and work together with the MoH and relevant stakeholders to achieve the goal of the Project.

Project Website:

The Project for Strengthening In-service Training System in Cambodia

https://www.jica.go.jp/oda/project/2004000/index.html...












